# ដំណាំអំពៅ



ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម
គំរោងឥណទានកម្មវិធី ធនាគារ អភិវឌ្ឍន៍ អាស៊ី
(ADB) លេខ 1445 - CAM (SF)
ឆ្នាំ ២០០៥

khmerebookfreedownload.blogspot.com

# ដំណាំអំពៅ



## I. ស្ថានភាពទូទៅ

អំពៅជាដំណាំមួយប្រភេទ ដែលប្រជាកសិករយើងស្គាល់ស្ទើរ គ្រប់គ្នាទាំងអស់ ហើយដំណាំនេះក៏បានដាំដុះលើផ្ទៃដីតូចៗ ស្ទើរពាសពេញនៃព្រះរាជាណាចក្រកម្ពុជាយើងដែរ ។

ជាទូទៅប្រជាកសិករតែងនិយមយកអំពៅមកគាបយកទឹកសំរាប់ហូបដូចជាភេសជ្ជៈធម្មតាឬគេនិយមហូបផ្ទាល់តែម្តង ។ សារៈសំខាន់នៃដំណាំនេះក្នុងប្រទេសយើង ក៏ដូចជាក្នុងភិភពលោក គេបានកែច្នៃទឹកអំពៅយកទៅធ្វើជាស្ករសដែលយើង

ត្រូវការចាំបាច់ខានមិនបានជារៀងរាល់ថ្ងៃ ។ ក្រៅពីសារៈសំខាន់សម្រាប់ធ្វើស្ករអំពៅនៅប្រទេសមួយចំនួនគេបានកែច្នៃទឹកអំពៅយកទៅធ្វើជាអាកុល ស្រា និងធ្វើជាចំណីសត្វហើយម្យ៉ាងទៀតកាកអំពៅគេបានយកទៅកែច្នៃធ្វើជាក្រដាស ក្តារបន្ទះ ។ល។ ចំពោះប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ ដំណាំអំពៅគឺគេបានកែច្នៃធ្វើស្ករក្នុងសិប្បកម្មតូចៗប៉ុណ្ណោះក្រៅពីនេះគឺប្រជាកសិករ យើងនិយមហូបទឹកអំពៅដូចជាភេសជ្ជៈធម្មតាប៉ុណ្ណោះ ។

## II. តំបន់ដាំដុះ

ជាទូទៅកសិករយើងតែងតែនិយមដាំដុះអំពៅនៅតំបន់តាមដងទន្លេ ដូចជានៅខេត្ត ក្រចេះ កំពង់ចាម កណ្តាល ព្រៃវែង ក្រៅពីតំបន់តាមដងទន្លេ គេអាចដាំដំណាំនេះនៅតាមតំបន់ដីខ្ពង់រាប ដីកោះ និងតាមជំរាលជើងភ្នំ លើដីក្រហម ឬ ដីខ្មៅ



ដូចជានៅតាម ខេត្តបាត់ដំបង ស្ទឹងត្រែង មណ្ឌលគិរី រតនគិរី ជាដើម ។ល។

## III. បរិស្ថាននៃដំណាំអំពៅ

អំពៅជាដំណាំមួយប្រភេទដែលទាមទារកំដៅខ្លាំងសំរាប់ការលូតលាស់ដងដើមក្នុងរយៈពេលលូតលាស់ដងដើម ស្លឹក ដំណាំ

នេះទាមទារសីតុណ្ហភាពខ្ពស់ជា មធ្យម ២៥ C ទៅ ៣០ C ក្នុងរយៈពេល ២៤ ម៉ោងលើកលែងតែដល់ដំណាក់កាលកកើតស្ករគឺ ២ ទៅ ៣ខែ មុនពេលកាប់ ទើបទាមទារសីតុណ្ហភាពទាបជាមធ្យម ១៨ ទៅ ២២ អង្សាសេ ដើម្បី អាចបង្កើតជាតិស្ករច្រើន ។

ដំណាំនេះក៏ជាដំណាំមួយដែលត្រូវការទឹកច្រើនបង្គួរដែរ ដូច្នេះដើម្បីធានាឱ្យបានផលល្អគឺយើងត្រូវ លៃយ៉ាងណាពេលដែលដំណាំស្ថិតក្នុងដំណាក់កាលលូតលាស់ខ្លាំងអាចចំពេលដែលមានភ្លៀងធ្លាក់ច្រើន ហើយផ្ទុយទៅវិញ ប្រមាណជា ២ ទៅ ៣



ខែមុនពេលប្រមូលផលអាចចំពេលដែលមានភ្លៀងធ្លាក់តិច ឬស្ទើរតែគ្មានភ្លៀងធ្លាក់ ទើបជាការប្រសើរក្នុងការផ្តល់ទិន្នផលស្ករខ្ពស់ ។

ប្រភេទដី ដែលល្អសម្រាប់ដំណាំអំពៅគឺដីល្បប់ល្បាយខ្សាច់ មិនជាំទឹក ដីច្រោះទឹកល្អ ដីដែលមានជីជាតិល្អ ដែលមានស្រទាប់ទី ១ ជ្រៅ និងជាដីដែលមាន pH 5,5 ទៅ 6,8 ។ ចំពោះប្រទេសកម្ពុជាយើង ដីដែលសមស្របសម្រាប់ដំណាំនេះ គឺដីល្បប់ល្បាយខ្សាច់តាមដងទន្លេ ដីក្រហម និងដីខ្មៅតាមតំបន់ខ្ពង់រាប ។ ដំណាំនេះដាំបានល្អនៅលើដីស្រទាប់ទី ១ រាក់ ( ជម្រៅស្រទាប់ទី ១ រាក់ជាង ២០ ស.ម ) ចំពោះដីដែលមានក្រួសក្រហមច្រើននោះមិនសមស្របសម្រាប់ ដំណាំនេះឡើយ ។

IV. **បច្ចេកទេសដាំដុះ និងថែរក្សា :**



## ក. រដូវកាលដាំដុះ

### - តំបន់ទាបនិងទួល

ជាទូទៅគេអាចចាប់ផ្តើមដាំក្នុងអំឡុងពេលខែវិច្ឆិកា ធ្នូ រហូតដល់ចុងខែមករា ហើយប្រមូលផលនៅអំឡុងខែសីហា កញ្ញា មុនពេលទឹកឡើងលិចចំការ ។ ការប្រមូលផលនៅក្នុងអំឡុងខែនេះគឺជាទូទៅគេយកអំពៅសម្រាប់គាបយកទឹកហូប ។ ចំពោះការដាំដុះសម្រាប់ធ្វើស្ករ ត្រូវប្រមូលផលក្នុងអំឡុងខែវិច្ឆិកា ធ្នូ ឬមករា គឺចំពេលដែលមានសីតុណ្ហភាពទាប ។ ដូច្នេះដំណាំអាចមានអាយុដល់ទៅ ១១ ខែឬ ១២ ខែ និងអាចដល់ ១៣ ខែ ។



- **តំបន់ខ្ពង់រាប**

ចំពោះតំបន់នេះគេអាចចាប់ផ្ដើមដាំក្នុងអំឡុងខែ មេសា ពេលដែល មានភ្លៀងធ្លាក់ដំបូងហើយគេអាចប្រមូលផលក្នុងអំឡុងខែមករា និងកុម្ភៈ ។ ដូច្នេះការប្រមូលផលក្នុងខែនេះដំណាំអាចមានអាយុប្រមាណជា ១០ ខែ ។

## ៦. ការរៀបចំដី

ការភ្ជួររាស់ជាទូទៅចំពោះដំណាំអំពៅក៏ប្រហាក់ប្រហែល និងដំណាំចំការផ្សេងៗទៀតដែរ ។ ការភ្ជួររាស់ធ្វើឡើងក្នុងគោលបំណងដើម្បីជ្រៃជ្រួយដីឱ្យផុសល្អដែលអាចបង្កឱ្យដំណាំដុះលូតលាស់ឆាប់ ម្យ៉ាងទៀតតាមរយៈការរៀបចំដីយើងអាចសម្លាប់ស្មៅសត្វល្អិត និងជម្ងឺមួយចំនួន ។ ជាធម្មតាគេអាចភ្ជួរ ២ សារ និងរាស់ជ្រួយដី ២ ទៅ ៣ សារ ដើម្បីឱ្យដីផុសល្អ ។ លក្ខណៈពិសេស នៃការភ្ជួររាស់គឺការ



ភ្ជួរលើកទី១ គេធ្វើនៅពេលដែលទឹកស្រកចុះផុតពីចំការ ( ចំពោះតំបន់មាត់ទន្លេ ) បន្ទាប់មកគេទុកដីហាលចោលរយៈពេលប្រមាណ ១០ ថ្ងៃ ហើយចាប់ផ្ដើមភ្ជួរលើកទី ២ បន្ទាប់ពីការភ្ជួរលើកទី ២ ត្រូវរាស់ដីឱ្យបានម៉ត់ល្អ ។ ចំពោះតំបន់ខ្ពង់រាបវិញ គេបានចាប់ផ្ដើមភ្ជួរដីលើកទី ១ ប្រមាណជា ១ ទៅ ២ ខែ មុនពេលដាំ ។ បន្ទាប់មកពេលដែលមានភ្លៀងធ្លាក់ល្មម ហើយគេអាចភ្ជួរលើកទី ២ រួចរាស់ឆ្វូតរង ឬ កាប់រណ្ដៅ និងចាប់ផ្ដើមការដាំដុះតែម្ដង ។

## គ. របៀបដាំ

ការដាំអំពៅគេអាចធ្វើបានច្រើនយ៉ាងគឺ គេអាចបណ្ដុះកូនជាមុនសិន ឬ ក៏ដាក់ដាំកំណាត់ដើមដែលមានភ្នែកតែម្ដង ។



- **ការបណ្ដុះកូន**

- វិធីនេះគឺគេបណ្ដុះកូនជាមុនសិន ហើយត្រូវបានគេយកទៅដាំនៅចំការពេលដែលកូននោះលាស់បានធំល្មម ( អាយុប្រមាណជា ១ ខែ ) វិធីនេះគេច្រើនអនុវត្តចំពោះការដាំក្នុងរណ្ដៅ ។

- ជាដំបូងគេត្រូវកាត់ជាកំណាត់ខ្លីៗ ដែលមានថ្នាំងមួយៗ រួចហើយគេដាក់តំរៀបគ្នាក្នុងថ្នាលមួយក្បែរប្រភពទឹកដើម្បីងាយស្រួលក្នុងការស្រោចស្រព ។

- កំណាត់ដើមអំពៅដែលគេតំរៀបគ្នានោះមិនត្រូវលុបដីឱ្យជិតតែម្ដងទេ ហើយត្រូវដាក់ភ្នែកថ្នាំងអំពៅនៅលើដើម្បីបង្កការងាយស្រួលក្នុងការដុះពន្លកហើយ



ដើម្បីឱ្យកាន់តែប្រសើរត្រូវគ្របចំបើងពីលើ ។

- ជាទូទៅគេត្រូវស្រោចទឹកមួយថ្ងៃម្តងដើម្បីឱ្យកូនអំពៅនោះលូតលាស់បានល្អ ។ ពេលដែលកូនអំពៅនោះលាស់បានល្អមានទំហំដើមប៉ុនម្រាមដៃ ហើយដែលមានអាយុប្រមាណជា ១ ខែទើបគេយកទៅដាំនៅចំការ ។

- ការដាក់ដាំកំណាត់ដើមៈ វិធីនេះគេអនុវត្តន៍ចំពោះដីចំការធំៗដែលជួនកាលការកាប់រណ្តៅអាចត្រូវចំណាយថវិកាច្រើន ។ ការដាំដុះតាមវិធីនេះគេអាចអនុវត្តន៍បានពេលដែលចំការមានដីសើមល្មម ។ វិធីនេះអាចចំណាយទុនតិច និងឆាប់រហ័សទៀតផងប៉ុន្តែវា មានគុណវិបត្តិម្យ៉ាង គឺអាចបណ្តាលឱ្យដើមដុះមិនបានល្អក្នុងចំការពេលដែលពុំមានភ្លៀងធ្លាក់គ្រប់គ្រាន់ ។



- **ការរៀបចំពូជ**

ជាទូទៅគេកាត់ពូជជាកង់ៗមាន ៣ ថ្នាំងនិងភ្នែក៣ ល្អៗ ។ ដើមដែលជ្រើសរើសយកមកធ្វើជាពូជជាដើមដែលមានអាយុប្រមាណជា ៧ ខែ ទើបជាពូជដែលមានគុណភាពល្អ។ មិនត្រូវយកផ្នែកខាងគល់ពេក ឬចុងពេកមកធ្វើពូជឡើយ ព្រោះវា





អាចដុះមិនសូវល្អ ។ ម្យ៉ាងទៀតជៀសវាង យកដើមណាស្គមហើយមានកើតជម្ងឺ ។ កំណាត់ដើមអំពៅ ដែលគេយកមកធ្វើ ពូជដាំរួមមាន : ថ្នាំង និងភ្នែក ( ពន្លក ) ៣ ល្អ ។

- មុនពេលដាំគេត្រូវឆ្វតរង ឬ គន្លង ដែលមាន ចន្លោះឃ្លាតពីគ្នា ០,៩០ម ទៅ ១,២០ ម ។ រួចហើយគេបោះពូជទៅ បាតរង ហើយគេត្រូវរាស់លុប ឬ ឆ្វតលុប តែម្តង ។

- ក្នុងការបោះពូជ គេអាចបោះ កំណាត់ពូជនូវចន្លោះឃ្លាតពីពូជមួយទៅពូជ មួយ ឬ ពីគុម្ពមួយទៅគុម្ពមួយឃ្លាត ពីគ្នា ប្រមាណ ជា ០,៥០ ទៅ ០,៦០ ម ។

-វិធីម្យ៉ាងទៀតគេអាចបោះទាំង ដើមវែង តែម្តងរួចហើយគេកាប់ដើម ជាកង់ៗក្នុងចំការតែម្តង ។

**-ការដាំក្នុងរណ្តៅ:** ចំពោះការដាំ

ក្នុងរណ្ដៅ គឺគេដាក់ក្នុងមួយរណ្ដៅពីរកំណាត់ពូជ ។ នៅបាតរណ្ដៅគេដាក់ជីធម្មជាតិលាយជាមួយជីគីមីបន្តិចគឺប្រមាណជា ៥០ ក្រាមជីគីមី និង ជីធម្មជាតិប្រមាណជា ០,៥ ទៅ ១,០ គ.ក្រ ក្នុងមួយរណ្ដៅ ។ ចន្លោះឃ្លាតនៃរណ្ដៅ ១ ម x ០,៨ម និងទំហំ ០,៣៥ម បួនជ្រុង ដែលមានជំរៅប្រមាណជា៣០ ស.ម ។ ការដាំដោយដាក់កំណាត់ដើមនេះ មានលក្ខណៈងាយស្រួលម្យ៉ាងគឺយើងចំណាយទុនតិច ពុំចាំបាច់ធ្វើការស្រោចស្រព ហើយដំណាំអាចដុះលូតលាស់បានអាស្រ័យទៅដោយទឹកក្នុងដី និងទឹកភ្លៀងធ្លាក់ ។ នៅប្រទេសកម្ពុជាយើង កសិករនិយមដាំអំពៅម្ដងហើយប្រមូលផលម្ដង ។ នៅប្រទេសគេភាគច្រើនពេលដែលគេដាំលើចំការធំៗគេដាំម្ដងហើយ



គេអាចប្រមូលផលរហូតដល់ ៣ ទៅ ៤ ដង ក្នុង អំឡុងពេល ៥ ឆ្នាំ ។ នៅប្រទេសជឿនលឿនខ្លះទៀតមានចំការអំពៅ ដែលមានអាយុរហូតដល់ទៅ ១០ ទៅ ១៥ឆ្នាំ ហើយគេអាចប្រមូលផលបានពី ៨ ទៅ ១២ ដង ។

**ឃ. ការដាក់ជី** : ដំណាំអំពៅជាដំណាំមួយប្រភេទដែលត្រូវការជីច្រើនគួរសម ក្នុងចំណោមជីជាតិចិញ្ចឹមសំខាន់ៗ ដំណាំអំពៅត្រូវការជីប៉ូតាស្យូម ច្រើនជាងគេព្រោះដំណាំអំពៅជាដំណាំមួយដែលបង្កើតជាតិស្ករ ។ បរិមាណនៃជាតិប៉ូតាស្យូមដែលត្រូវដាក់ស្មើរស្មើនឹងជីអាហ្សូតដែរ ។ចំពោះលក្ខខណ្ឌប្រទេសកម្ពុជាយើងដែលកសិករដាំមួយឆ្នាំតែម្តង និងប្រមូលផលតែម្តងនោះ គឺយើងអាចណែនាំឱ្យកសិករយើងដាក់ជី ១៥.១៥.១៥ ប្រមាណ ២០០ គ.ក្រ/ហ.ត ។ បើករណីយើងដាំអំពៅសំរាប់ធ្វើ





ស្ករដូច្នេះយើងត្រូវដាក់ជីគីមីនូវបរិមាណជា ៤០០ គ.ក្រជី ១៥.១៥.១៥ ក្នុងមួយហ.ត ដើម្បីធានាបានទិន្នផលស្ករច្រើន ។ ការដាក់ជីលើដំណាំអំពៅជាទូទៅ គឺគេដាក់តែម្តងប៉ុណ្ណោះនៅពេលដាំ ហើយគេកម្រនឹងដាក់ ជីអ៊ុយរ៉េបំប៉នម្តងទៀត ណាស់ ព្រោះអាចបណ្តាលឱ្យប៉ះពាល់ដល់ទិន្នផលស្ករ ។ ក្នុងករណីចំការដែលយើងដាំម្តងហើយធ្វើការប្រមូលផលពី ២ ទៅ ៣ ដងនោះការដាក់ជីត្រូវដាក់ក្រោយ ពេលប្រមូលផលលើកទី ១ជាថ្មី ម្តងទៀតនូវបរិមាណជីដូចទៅនឹងការដាក់ នៅពេលដាំ ប៉ុន្តែត្រូវបន្ថែមជីអ៊ុយរ៉េមួយកិរិតថែមទៀតគឺប្រមាណពី ៥០ ទៅ ១០០ គ.ក្រ /ហ.ត ដើម្បីជំនួយដល់ការដុះលូតលាស់របស់កូនអំពៅថ្មី ។

**៦. ការសំអាតស្មៅ:** ការសំអាតស្មៅមានសារៈប្រយោជន៍ណាស់សំរាប់



ដំណាំអំពៅ ។ ការសំអាតស្មៅគេត្រូវចាប់ផ្តើមអនុវត្តចាប់ពីពេលដែលយើងដាំរហូតដល់ដើមអំពៅមានស្លឹកធំជិតដីចំការ ។ បើក្នុងចំការមានស្មៅតាំងពីពេលដាំរហូតដល់ពេលអំពៅមានអាយុ ៤៥ ថ្ងៃ គឺអាចបណ្តាលឱ្យថយចុះទិន្នផលស្ករហូតដល់ ១២ % បើធៀបទៅនឹងចំការដែលគ្មានស្មៅ ។ ត្រូវពូនគល់ដើម្បីជំនួយដល់ការដុះលូតលាស់នៃខ្នែងអំពៅ ដែលជាកត្តាមួយយ៉ាងសំខាន់ក្នុងការផ្តល់ទិន្នផល ។ ការជំរះស្មៅ គឺយើងអាចធ្វើដោយចប ហើយចំពោះដីចំការធំ គេអាចធ្វើដោយដោយគ្រឿងយន្ត ។ ចំពោះប្រទេសកម្ពុជាយើងពេលដែលគេដាំនៅរដូវទឹកសំរក ក្នុងខែវិច្ឆិកា ធ្នូ ជាដំបូងគេអាចជំរះស្មៅមួយដង ឬ ពីរដងហើយរហូតដល់ពេលធ្លាក់ភ្លៀង ស្មៅដុះថ្មីទើបគេជំរះម្តងទៀត ។

## V. ការប្រមូលផល

ការប្រមូលផលដំណាំអំពៅនៅប្រទេសកម្ពុជាយើង គឺគេអាចធ្វើឡើងដោយយោងតាមលក្ខខណ្ឌអាកាសធាតុ និងទីផ្សារ ។ ប៉ុន្តែជាទូទៅគេប្រមូលផលពេលដែលដំណាំមានអាយុប្រមាណជា ១០ ទៅ ១៣ ខែបន្ទាប់ពីដាំ ។ ចំពោះការដាំអំពៅសម្រាប់គ្រាន់តែលក់ដើម្បីគាបទឹកហូប ការប្រមូលផលពុំសូវមានបញ្ហាអ្វីចោទឡើងទេ គឺគេអាចប្រមូលផលក្នុងអំឡុងខែកញ្ញា គឺពេលអំពៅមានអាយុ ១០ ខែមុនពេលទឹកលិច ថ្វីត្បិតតែក្នុងពេលនេះក្នុងដើមពុំសូវមានជាតិស្ករក៏ដោយ ។ ចំពោះការដាំដុះអំពៅសំរាប់ធ្វើស្ករ ពេលវេលានៃការប្រមូលផលគឺក្នុងអំឡុងពេលខែធ្នូ ឬ មករា ព្រោះត្រឹមខែនេះអំពៅមានអាយុពី ១២ ទៅ ១៣ ខែ និងជាពេលដែលអាកាសធាតុត្រជាក់





ហើយអំពៅមានជាតិស្ករច្រើន ។ ការប្រមូលផលនៅចំការធំៗជួនកាលគេដុតចំការជាមុនសិន ទើបគេកាប់ដើមអំពៅក្នុងករណីនេះ គេត្រូវកាប់អំពៅភ្លាម និងប្រញាប់យកទៅរោងចក្រ ព្រោះបើទុកចោលលើសពី ៣ ថ្ងៃអាចបណ្តាលឱ្យខូចគុណភាពស្ករ ។